ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តក្រចេះ

សាលក្រមព្រហ្មទណ្ឌ

លេខ ៥៥០ "ខ"

ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២៣

-សំណុំរឿងព្រហ្មទណ្ឌលេខ ០៦៣

ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២១

-សំណុំរឿងស៊ើបសួរលេខ ២៤២

ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២១

-សំណុំរឿងជំនុំជម្រះលេខ ២៥៣

ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២២

តាងនាមប្រជារាស្ត្រខ្មែរ

សាលាដំបូងខេត្តក្រចេះ

-បានបើកសវនាការជាសាធារណៈនៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៣ វេលាម៉ោង ០២ និង៣០នាទី រសៀល ដែលមានសមាសភាពដូចតទៅ÷

ចៅក្រមជំនុំជម្រះ

លោកស្រី [redacted] ចៅក្រមសាលាដំបូង

តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូង

ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូង

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ០៦៣ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ ២០២១ ដែលមានជនជាប់ចោទ÷

១-ឈ្មោះ [redacted] ឈង ភេទប្រុស អាយុ៧៣ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ កម្រិតវប្បធម៌ថ្នាក់ទី០៥ចាស់ មុខរបរកសិករ ទីកន្លែងកំណើតភូ[redacted] ខេត្តក្រចេះ ទីលំនៅបច្ចុប្បន្ននៅភូមិហាន់ជ័យ១ ឃុំហាន់ជ័យ ស្រុកឆ្លង ខេត្តក្រចេះ ឪពុកឈ្មោះ [redacted] រឿន "ស្លាប់" ម្តាយឈ្មោះ [redacted] យឿន "ស្លាប់" ប្រពន្ធឈ្មោះ [redacted] តឹមស្រៀន មានកូន០៩នាក់ ជានីតិជន ទោសពីមុន÷គ្មាន។(ក្រៅឃុំ)

-លោក [redacted] ជាមេធាវីការពារសិទ្ធិ។(អវត្តមាន)

-លោក [redacted] ជាមេធាវីការពារសិទ្ធិ។(អវត្តមាន)

-លោក [redacted] ជាមេធាវីការពារសិទ្ធិ។

២-ឈ្មោះ [redacted] សុខុន ហៅ ត្រាច ភេទប្រុស អាយុ៥៧ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ កម្រិតវប្បធម៌ថ្នាក់ទី០៣ចាស់ មុខរបរកសិករ ទីកន្លែងកំណើតភូ[redacted] ខេត្តក្រចេះ ទីលំនៅបច្ចុប្បន្នភូមិហាន់ជ័យ២ ឃុំហាន់ជ័យ ស្រុកឆ្លង ខេត្តក្រចេះ ឪពុកឈ្មោះ [redacted] ហួត "ស្លាប់ ម្តាយឈ្មោះ [redacted] តា "រស់" ប្រពន្ធឈ្មោះ [redacted] កល្យាន មានកូន០៣នាក់ ជានីតិជន ទោសពីមុន÷គ្មាន។(ក្រៅឃុំ)

-លោក [redacted] ជាមេធាវីការពារសិទ្ធិ។(អវត្តមាន)

Scanned with CamScanner

៣-ឈ្មោះ [redacted] **គីមឆាន** ភេទប្រុស អាយុ៦៩ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ កម្រិតវប្បធម៌ថ្នាក់ទី០៧ចាស់ មុខរបរកសិករ ទីកន្លែងកំណើតភូ[redacted] ខេត្តក្រចេះ ទីលំនៅបច្ចុប្បន្ននៅភូមិទឹកជ្រៅ ឃុំទឹកជ្រៅ ស្រុកតំបែរ ខេត្តត្បូងឃ្មុំ ឪពុកឈ្មោះ [redacted] **រឿន** "ស្លាប់" ម្តាយឈ្មោះ [redacted] **ឃឿន** "ស្លាប់" ប្រពន្ធឈ្មោះ [redacted] **សុខខា** មានកូន០៣នាក់ ជានីតិជន ទោសពីមុន÷គ្មាន។(ក្រៅឃុំ)

-លោក [redacted] ជាមេធាវីការពារសិទ្ធិ។

៤-ឈ្មោះ [redacted] **សាមឿន** ភេទប្រុស អាយុ៦២ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ កម្រិតវប្បធម៌ថ្នាក់ទី០៣ចាស់ មុខរបរកសិករ ទីកន្លែងកំណើតនៅភូ[redacted] ខេត្តក្រចេះ ទីលំនៅបច្ចុប្បន្នភូមិហាន់ជ័យ២ ឃុំហាន់ជ័យ ស្រុកឆ្លូង ខេត្តក្រចេះ ឪពុកឈ្មោះ [redacted] **ជឿន** "ស្លាប់" ម្តាយឈ្មោះ[redacted] **ហាន** "រស់" ប្រពន្ធឈ្មោះ[redacted] **សុខហេង** មានកូន០៦នាក់ ជានីតិជន ទោសពីមុន÷គ្មាន។(ក្រៅឃុំ)

-លោក [redacted] ជាមេធាវីការពារសិទ្ធិ។(អវត្តមាន)

-លោក [redacted] ជាមេធាវីការពារសិទ្ធិ។(អវត្តមាន)

-លោក [redacted] ជាមេធាវីការពារសិទ្ធិ។

ជាប់ចោទពីបទ: **ហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត** ប្រព្រឹត្តនៅចំណុចភូមិជ្រោយថ្មក្រោម ឃុំឆ្លូង ស្រុកឆ្លូង ខេត្តក្រចេះ កាលពីថ្ងៃទី៣១ ខែមករា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **២៥៣** នៃច្បាប់ភូមិបាល។

-ជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **វាសនា** ភេទប្រុស អាយុ៤៨ឆ្នាំ ជាតិខ្មែរ អាសយដ្ឋានបច្ចុប្បន្នសង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិ។

<u>អត្ថហេតុកើតមានឡើងដូចតទៅ</u>

កាលពីថ្ងៃទី៣១ ខែមករា ឆ្នាំ២០២១ ឈ្មោះ [redacted] **ធារ៉ុង** ហៅ [redacted] **ភារ៉ុង** ភេទប្រុស អាយុ៤០ឆ្នាំ, ឈ្មោះ [redacted] **សាមឿន** ភេទប្រុស អាយុ៦២ឆ្នាំ, ឈ្មោះ[redacted] **ឈង** ភេទប្រុស អាយុ៧៣ឆ្នាំ, ឈ្មោះ [redacted] **គីមឆាន** ភេទប្រុស អាយុ៦៩ឆ្នាំ និងឈ្មោះ [redacted] **សុខុន** ហៅ **ច្រាច** ភេទប្រុស អាយុ៥៧ឆ្នាំ បានជួលឡានជីកដីទៅចាក់លុបលើដីរបស់ឈ្មោះ [redacted] **វាសនា** ភេទប្រុស អាយុ៤៨ឆ្នាំ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១០០១០១០២-០៦០៦ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២០។ លុះដល់ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២១ លោក [redacted] **ប៊ុនមុ** ភេទប្រុស អាយុ៤៨ឆ្នាំ ជាអនុប្រធានមន្ទីរសុរិយោដីខេត្តក្រចេះ រួមជាមួយប្រធានភូមិបាលស្រុកឆ្លូង និងមន្ត្រីបច្ចេកទេស បានចុះទៅណែនាំឈ្មោះខាង

លើកុំឱ្យបន្តចាក់ដីលុបលើដីរបស់ឈ្មោះ [redacted] វាសនា ទៀត។ ប៉ុន្តែឈ្មោះខាងលើមិនបានស្តាប់តាមការណែនាំរបស់លោក [redacted] ឫទ្ធុម ហើយនៅតែបន្តចាក់ដីលុបដដែល។ ក្រោយមកលោកព្រះរាជអាជ្ញារងឈ្មោះ [redacted] សុភ័ក្ត្រ បានចុះទៅអនុវត្តដីកាសម្រេចរក្សាការពារនៅទីតាំងដីខាងលើទើបឈ្មោះខាងលើបានបញ្ឈប់សកម្មភាពចាក់ដី។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ២១៦ អ.យ.ក ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងខេត្តក្រចេះ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ១៨៤ អ.ក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តក្រចេះ។

-បានឃើញ ដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ ១៥៥០ ព.ស/២២ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តក្រចេះ។

<u>ពេលសវនាការ</u>

-ជនជាប់ចោទឈ្មោះ [redacted]ឈង បានឆ្លើយថា: កាលពីថ្ងៃទី៣១ ខែមករា ឆ្នាំ២០២១ រូបខ្លួន, ឈ្មោះ [redacted] សាមឿន, ឈ្មោះ [redacted]គីមឆាន និងឈ្មោះ [redacted] សុខុន និងកូនចៅជាច្រើនទៀត បានឱ្យឡានដឹកដីមកចាក់លើដីដែលមានទីតាំងនៅភូមិជ្រោយថ្មក្រោម ឃុំឆ្លង ស្រុកឆ្លង ខេត្តក្រចេះ អស់ប្រហែល៥០០ឡាន (ក្នុងមួយឡានតម្លៃប្រាំម៉ឺនរៀល) មូលហេតុដែលខ្លួនចាក់ដីនោះ ដើម្បីយកដីចែកកូនចៅធ្វើផ្ទះនៅ ដោយដីដែលខ្លួនចាក់នោះមានទំហំប្រហែល៤០ម៉ែត្រការ៉េ ហើយការចាក់ដីនោះក៏បានសុំច្បាប់ពីអាជ្ញាធរឃុំហាន់ជ័យ និងឃុំឆ្លងផងដែរ ប៉ុន្តែខ្លួនមិនបានទៅសុំច្បាប់ពីអាជ្ញាធរឃុំផ្កាល់នោះទេ ដោយមិនដឹងថាអ្នកណាជាអ្នកទៅសុំច្បាប់នោះទេ នៅពេលនោះខ្លួនមិនដឹងថាការចាក់នោះបានបំពានចូលទៅលើដីឈ្មោះ [redacted] វាសនា នោះទេ ពីព្រោះឈ្មោះ [redacted] វាសនា គ្មានដីនៅជាប់ជាមួយដីរបស់ខ្លួនដែលមានទីតាំងនៅភូមិជ្រោយថ្មក្រោម ឃុំឆ្លង ស្រុកឆ្លង ខេត្តក្រចេះ ដោយដីខ្លួនចាក់នោះ គឺចាក់ចូលទៅក្នុងប្រឡាយ ដើម្បីឱ្យស្មើនឹងស្រែរបស់ខ្លួន ដោយប្រឡាយនោះជាប្រឡាយរបស់រដ្ឋ។ បន្ទាប់មកខ្លួនក៏បានបន្តចាក់ដីទៅក្នុងប្រឡាយរបស់រដ្ឋរហូតដល់ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២១ ទើបមានការហាមលើការចាក់ដីនោះ ទើបខ្លួនឈប់ចាក់ដីបន្តទៀត។ នៅពេលដែលសមត្ថកិច្ចបានចុះទៅធ្វើការហាមឃាត់ការចាក់ដីនោះ គឺខ្លួនពុំមានវត្តមាននៅទីនោះទេ ហើយខ្លួនក៏ឈប់ធ្វើសកម្មភាពចាក់ដីនោះរហូតមកដល់ពេលនេះ។ ដីស្រែដែលនៅជាប់ប្រឡាយគឺដីរបស់ខ្លួន ហើយប្រឡាយដែលជាប់នឹងដីស្រែរបស់ខ្លួននោះ គឺជាប្រឡាយរបស់រដ្ឋ ដែលខ្លួនបានយកដីទៅចាក់បំពេញ។ ខ្លួនមិនបានចាក់ដីបំពាន ឬធ្វើការកាន់កាប់ដីរបស់ឈ្មោះ តាន់ វាសនា នោះទេ គឺខ្លួនគ្រាន់តែចាក់ដីបំពេញប្រឡាយរបស់រដ្ឋយកមកធ្វើជាដីរបស់ខ្លួនប៉ុណ្ណោះ។ ដីស្រែរបស់ខ្លួន គឺមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ។

-ជនជាប់ចោទឈ្មោះ [redacted] **សុខុន** ហៅ **ត្រាច** បានឆ្លើយថា: ជីដែលមានទីតាំងនៅភូមិជ្រោយថ្មក្រោម ឃុំឆ្នង ស្រុកឆ្នង ខេត្តក្រចេះ ដែលត្រូវបានចាក់ជីទៅលើនោះគឺខ្ញុំនអត់ដឹងថាជីនោះមានទំហំប៉ុន្មានម៉ែត្រការ៉េនោះទេ ពីព្រោះជីនោះគឺជាជីកៅស៊ូមរតកខាងប្រពន្ធរបស់ខ្ញុំនឈ្មោះ [redacted] កល្យាណ ហើយជីនោះមិនទាន់បានចុះបញ្ជីត្រឹមត្រូវនៅឡើយទេ។ ជីនោះជារបស់ឈ្មោះ [redacted] ធារ៉ុង ភេទប្រុស, ឈ្មោះ [redacted] សាមឿន ភេទប្រុស, ឈ្មោះ ទី ឈង ភេទប្រុស, ឈ្មោះ[redacted]គីមឆាន ភេទប្រុស និងឈ្មោះ[redacted] កល្យាណ ដែលត្រូវជាប្រពន្ធរបស់ខ្ញុំន ហើយអ្នកទាំងប្រាំនាក់នោះ គឺបានសហការគ្នាដើម្បីចាក់ជីនោះប៉ុន្តែខ្ញុំនអត់ដឹងថាមានការយល់ព្រមពីអាជ្ញាធរអត់ទេ។ កាលពីថ្ងៃទី៣១ ខែមេសា ឆ្នាំ ២០២១ នៅពេលកំពុងចាក់ជីនោះ គឺខ្ញុំនអត់បាននៅកន្លែងកើតហេតុនោះទេ គឺខ្ញុំននៅធ្វើស្រែនៅម្ខុំព្រែកឬស្សី ហើយខ្ញុំនដឹងថាជីរបស់ឈ្មោះ [redacted] វាសនា ជាប់នឹងជីនោះនៅព្រំខាងជើង តែខ្ញុំនអត់ដឹងថាជីរបស់ឈ្មោះ[redacted] វាសនា មានទំហំប៉ុន្មានម៉ែត្រការ៉េនោះទេ ហើយថែមទាំងមិនដឹងថាជីនោះបានចុះបញ្ជីអត់នោះទេ។ នៅពេលកំពុងចាក់ជីនោះខ្ញុំនឮថាមានការហាមឃាត់លើការចាក់ជីនោះ ហើយក៏ផ្អាកសកម្មភាពចាក់ជីនោះទៅ រួចហើយខ្ញុំនក៏អត់មានធ្វើសកម្មភាពណាមួយនៅលើជីនោះទេ ហើយក៏មិនដឹងថាការចាក់ជីនោះបានបំពានទៅលើជីរបស់ឈ្មោះ [redacted] វាសនា នោះដែរ។ ចំពោះឈ្មោះ [redacted] ធារ៉ុង ត្រូវជាកូយប្រសារ, ឈ្មោះ [redacted]សាមឿន ត្រូវជាបងថ្លៃ, ឈ្មោះ[redacted]ឈង ក៏ជាបងថ្លៃ និងឈ្មោះ[redacted] គីមឆាន ក៏ជាបងថ្លៃខ្ញុំនដែរ។

-ជនជាប់ចោទឈ្មោះ [redacted] **គីមឆាន** បានឆ្លើយថា: កាលពីថ្ងៃទី៣១ ខែមករា ឆ្នាំ ២០២២ រូបខ្ញុំន, ឈ្មោះ [redacted] ធារ៉ុង, ឈ្មោះ [redacted]សាមឿន, ឈ្មោះ[redacted]ឈង, ឈ្មោះ[redacted]គីមឆាន និងឈ្មោះ[redacted]សុខុន បានសហការព្រមព្រៀងជួលឡានដីកជីមកចាក់ទៅលើជីរដូវដើម្បីលុបប្រឡាយ (មិនដឹងទំហំប៉ុណ្ណាទេ) មានទីតាំងនៅភូមិជ្រោយថ្មក្រោម ឃុំឆ្នង ស្រុកឆ្នង ខេត្តក្រចេះ ដោយខ្ញុំនមិនដឹងថាមានការអនុញ្ញាតពីអាជ្ញាធរមូលដ្ឋានទេ។ ចំពោះការចាក់ជីនោះមានចំនួនប្រហែល៦០០ឡាន ដោយក្នុងមួយឡានតម្លៃ ២៤.០០០ (ពីរម៉ឺនប្រាំបួនពាន់)រៀល ដើម្បីលុបប្រឡាយជីរបស់រដ្ឋធ្វើផ្លូវចូលស្រែរបស់ពួកខ្ញុំនដែលជីស្រែនោះមានទទឹង៦១ម៉ែត្រ និងបណ្តោយ១៣៦ម៉ែត្រ។ នៅថ្ងៃទី៣១ ខែមករា ឆ្នាំ ២០២២ ខ្ញុំននៅកន្លែងចាក់ជីនោះ ហើយខ្ញុំនមិនដឹងថាឡានដីកជីបានចាក់បំពានទៅលើជីរបស់ឈ្មោះ [redacted] វាសនា នោះទេ។ពេលឡានកំពុងចាក់ជីស្រាប់តែមានសមត្ថកិច្ចហាមឃាត់ ហើយខ្ញុំនក៏ផ្អាកការចាក់ជីរហូតដល់ពេលនេះមិនបានធ្វើសកម្មភាពអ្វីនោះទេ។ ខ្ញុំនដឹងថាជីរបស់ឈ្មោះ [redacted] វាសនា នៅភូមិជ្រោយថ្មក្រោម ឃុំឆ្នង ស្រុកឆ្នង ខេត្តក្រចេះ មានជាប់ព្រំជីរបស់ឈ្មោះ [redacted] សុខុន ហើយការចាក់ជីនោះមិនបានចាក់បំពានទៅលើជីរបស់ឈ្មោះ [redacted] វាសនា នោះទេ។

Scanned with CamScanner

-ជនជាប់ចោទឈ្មោះ [redacted] សាមឿន បានឆ្លើយថា: កាលពីថ្ងៃទី៣១ ខែមករា ឆ្នាំ ២០២១ រូបខ្ញុំ, ឈ្មោះ [redacted] ឈង, ឈ្មោះ [redacted] គីមឆាន និងឈ្មោះ [redacted] សុខុន និងញាតិជា ច្រើនទៀត បានឱ្យឡានដឹកដីមកចាក់ដីដែលមានទីតាំងនៅភូមិជ្រោយថ្មក្រោម ឃុំឆ្នង ស្រុកឆ្នង ខេត្តក្រចេះ អស់ប្រហែល៥០០ឡាន មូលហេតុដែលខ្ញុំនចាក់ដីនោះ ដើម្បីយក ដីចែកកូនចៅធ្វើផ្ទះនៅ ដោយដីដែលខ្ញុំនចាក់នោះមានទំហំប្រហែល៣០ម៉ែត្រការ៉ ហើយការចាក់ដីនោះក៏បានសុំច្បាប់ពីអាជ្ញាធរដែរ ប៉ុន្តែខ្ញុំនមិនមែនជាអ្នកទៅសុំច្បាប់ ដោយផ្ទាល់នោះទេ នៅពេលនោះខ្ញុំនមិនដឹងថាការចាក់នោះបានបំពានចូលទៅដីឈ្មោះ តាន់ វាសនា ហើយខ្ញុំនក៏បានចាក់ដីរហូតដល់ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២២ ទើបមាន តំណាងអយ្យការចុះអនុវត្តដីការរក្សាការពារហាមឃាត់លើការចាក់ដីនោះ ទើបខ្ញុំនឈប់ ចាក់ដីបន្តទៀត។ ខ្ញុំនមិនមានចេតនាចាក់ដីបំពានទៅលើដីរបស់ឈ្មោះ [redacted] វាសនា ទេ តែខ្ញុំនដឹងថាឈ្មោះ [redacted] វាសនា មានដីមួយកន្លែងស្ថិតនៅខាងជើងដីរបស់ខ្ញុំន នៅភូមិ ជ្រោយថ្មក្រោម ឃុំឆ្នង ស្រុកឆ្នង ខេត្តក្រចេះ ហើយចាប់តាំងពីពេលនោះមកខ្ញុំនឈប់ធ្វើ សកម្មភាពចាក់ដីនោះរហូតមកដល់ពេលនេះ។ ដីនោះមានទីតាំងនៅភូមិជ្រោយថ្មក្រោម ឃុំឆ្នង ស្រុកឆ្នង ខេត្តក្រចេះ គឺមានទំហំក្បាល១៤០ម៉ែត្រ និងបណ្តោយមានទំហំប្រហែល ៦០ម៉ែត្រ មិនមែនជាកម្មសិទ្ធិរបស់ខ្ញុំនទេ គឺជាដីរបស់ឪពុកម្តាយក្មេកឈ្មោះ [redacted] គឿន និង ឈ្មោះ [redacted] ឃឿន ដែលបានប្រគល់ឱ្យមកប្រពន្ធខ្ញុំននៅថ្ងៃខែឆ្នាំមិនចាំ ដោយមានលិខិត ផ្ទេរសិទ្ធិតែមិនដឹងលេខប៉ុន្មានទេ។ ការចាក់ដីនោះគឺជាការចាក់ដីបំពេញប្រឡាយដែលជា ប្រឡាយរបស់រដ្ឋដែលប្រឡាយនោះមានទទឹងប្រហែល២០ម៉ែត្រ និងបណ្តោយប្រហែល ២០០ម៉ែត្រ។ រីឯដីរបស់ឈ្មោះ [redacted] វាសនា មិននៅក្បែរនោះទេ។

-តាមអំណានចម្លើយរបស់ជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **វាសនា** បានបញ្ជាក់ថា: កាលពីថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០០១ ខ្ញុំនបានទិញដីមួយកន្លែង មានទំហំ ២.៩៧១ម៉ែត្រការ៉ ដែលទីតាំងស្ថិតនៅភូមិជ្រោយថ្មក្រោម ឃុំឆ្នង ស្រុកឆ្នង ខេត្តក្រចេះ ពីឈ្មោះ [redacted] សុន និងប្រពន្ធឈ្មោះ [redacted] សំអយ ក្នុងតម្លៃ ៩៥០ (ប្រាំបួន រយហាសិប) ដុល្លារអាមេរិក ដោយមានបំណុលសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ក.រ ០០៣០៤៨ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៨ ចេញដោយប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង និងសុរិយោដី ខេត្តក្រចេះ។ ក្រោយមក នៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ ២០២០ ខ្ញុំនបានចាក់បំពេញដីដែលមានបណ្តោយប្រវែង៥៧ម៉ែត្រ ទទឹងទី១ ប្រវែង២៥ ម៉ែត្រ និងទទឹងទី២ ប្រវែង១០ម៉ែត្រ នៅក្នុងដីដែលមាននៅក្នុងបំណុលសម្គាល់សិទ្ធិកាន់កាប់ អចលនវត្ថុខាងលើ នាខណៈពេលនោះស្រាប់តែឈ្មោះ [redacted] សុខុន, ឈ្មោះ [redacted] សាមឿន, ឈ្មោះ [redacted] ឈង, លោកមេឃុំឆ្នងឈ្មោះ [redacted] ចាំង និងលោកអភិបាលស្រុកឆ្នងឈ្មោះ

[redacted] សុជា បានចូលមកហាមឃាត់មិនឱ្យខ្ញុំបន្តចាក់ដីលើដីដែលជាកម្មសិទ្ធិរបស់ខ្ញុំ ទើបខ្ញុំបញ្ឈប់ការចាក់បំពេញដីរបស់ខ្ញុំតែម្តង។ លុះនៅក្នុងឆ្នាំ២០២០ ខាងមន្ទីរសុរិយោដីបានចុះធ្វើប្តង់ជាប្រព័ន្ធ និងបានចេញនូវវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ១០០១០១០២-០៦០៦ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២០ ចេញដោយមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង និងសុរិយោដី ខេត្តក្រចេះ។ បន្ទាប់មកនៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០២១ ឈ្មោះ[redacted] សាមឿន, ឈ្មោះ[redacted] ឈង, ឈ្មោះ[redacted] សុខុន, ឈ្មោះ[redacted] ធារ៉ុង, ឈ្មោះ[redacted] ម៉ាឡៃ, ឈ្មោះ[redacted] ណារ៉ុន, ឈ្មោះ[redacted] ស្រីពេជ្រ, ឈ្មោះ[redacted] កល្យាន និងឈ្មោះ[redacted] គីមឆាន បានយករថយន្តដីកដីទៅចាក់ក្នុងដីដែលខ្ញុំមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុត្រឹមត្រូវតាមច្បាប់ខាងលើ រួចប្អូនរបស់ខ្ញុំឈ្មោះ[redacted] ជីវ៉ា បានទៅប្តឹងលោកអភិបាលស្រុកឆ្លង ដើម្បីឱ្យលោកអភិបាលស្រុកឆ្លងចុះមកហាមឃាត់អ្នកដែលមានឈ្មោះខាងលើមិនឱ្យចាក់ដីទៀត។ បន្ទាប់មកនៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០២១ ស្រាប់តែឈ្មោះ[redacted] សាមឿន, ឈ្មោះ[redacted] ឈង, ឈ្មោះ[redacted] សុខុន, ឈ្មោះ[redacted] ធារ៉ុង, ឈ្មោះ[redacted] ម៉ាឡៃ, ឈ្មោះ[redacted] ណារ៉ុន, ឈ្មោះ[redacted] ស្រីពេជ្រ, ឈ្មោះ[redacted] កល្យាន និងឈ្មោះ[redacted] គីមឆាន នៅតែបន្តចាក់ដីលើដីកម្មសិទ្ធិរបស់ខ្ញុំ ព្រមទាំងដកបង្គោលដីរបស់ខ្ញុំប្រហែល១០បង្គោល ដែលមានប្រវែងប្រហែល៣០ម៉ែត្រ ទៀតផង។ខ្ញុំសូមទាមទារសំណងជម្ងឺចិត្តចំនួន៥០.០០០(ប្រាំម៉ឺន)ដុល្លារអាមេរិក។

-សាក្សីឈ្មោះ[redacted] ប្ញទុម បានបញ្ជាក់ថា: កាលពីថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២១ ខ្ញុំនចុះទៅកន្លែងកើតហេតុរួមមានគ្នាចំនួនបួននាក់ គឺរូបខ្ញុំនជាអនុប្រធានមន្ទីរសុរិយោដីខេត្តក្រចេះ, លោកប្រធានការិយាល័យភូមិបាលស្រុកឆ្លងឈ្មោះ[redacted] សិទ្ធិគុណ, មន្ត្រីភូមិបាលឈ្មោះ[redacted] ចាន់ និងមន្ត្រីមន្ទីរដែនដីឈ្មោះ[redacted] ម៉េង ដើម្បីទៅសួរនាំរកលិខិតស្នាម ដោយសារតែខ្ញុំនធ្លាប់បានដោះស្រាយរឿងដីនៅកន្លែងនោះកន្លងមក ហើយក៏ដឹងថាដីនេះគឺបានចេញប្តង់ប្រព័ន្ធដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ៦០៦ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ឈ្មោះ[redacted] វាសនា ដែលដីនោះមានទីតាំងនៅភូមិជ្រោយថ្មក្រោម ឃុំឆ្លង ស្រុកឆ្លង ខេត្តក្រចេះ។ ខណៈពេលដែលខ្ញុំនបានទៅដល់កន្លែងកើតហេតុបានឃើញគំនរដីដែលឈ្មោះ[redacted] សុខុន, ឈ្មោះ[redacted] ធារ៉ុង, ឈ្មោះ[redacted] សាមឿន, ឈ្មោះ[redacted] ឈង, ឈ្មោះ[redacted] គីមឆាន និងបក្ខពួកមានគ្នាប្រហែលចំនួនប្រាំនាក់កំពុងតែឈរនៅលើទីតាំងដីដែលគេកំពុងចាក់នោះ ហើយខ្ញុំនបានសុំឱ្យពួកគាត់បង្ហាញឯកសារ ប៉ុន្តែពួកគាត់មិនបានបង្ហាញឯកសារនោះទេ ដោយពួកគាត់ឱ្យខ្ញុំនបង្ហាញឯកសារដល់ពួកគាត់មុន ទើបគាត់បង្ហាញឯកសាររបស់ពួកគាត់វិញ។ បន្ទាប់មកខ្ញុំនបានឱ្យមន្ត្រីខាងភូមិបាលស្រុកឆ្លងទៅយកឯកសារចម្លង (ប្តង់កម្មសិទ្ធិរបស់ឈ្មោះ[redacted] វាសនា) ទៅ

បង្ហាញពួកគាត់ហើយពួកគាត់ក៏បង្ហាញឯកសារមកវិញ ប៉ុន្តែឯកសាររបស់ពួកគាត់គឺគ្រាន់តែលិខិតកាន់កាប់ដីដែលចុះហត្ថលេខា និងត្រារបស់មេឃុំ ព្រមទាំងមានលិខិតអនុញ្ញាតឱ្យចាក់ដីរបស់លោកមេឃុំហាន់ជ័យ។ ក្រោយពីខ្ញុំបានពិនិត្យឯកសាររួចហើយ ខ្ញុំបានប្រាប់ពួកគាត់ថាដីនោះមានប្តង់ត្រឹមត្រូវសូមកុំធ្វើអ្វី ប៉ះពាល់ដល់សិទ្ធិរបស់គេ ស្រាប់តែឈ្មោះ [redacted] សុខុន, ឈ្មោះ [redacted] ធារ៉ុង, ឈ្មោះ [redacted] សាមឿន, ឈ្មោះ [redacted] ឈង, ឈ្មោះ [redacted] គីមឆាន និងបក្ខពួកបានស្រែកហោកញ្ជ្រៀវមកលើខ្ញុំ ដោយមិនបានកាន់អ្វីក្នុងដៃនោះទេ ហើយពេលនោះខ្ញុំក៏ត្រឡប់មកវិញ។ ចំពោះដីដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ៦០៦ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២០ របស់មន្ទីរសុរិយោដីខេត្តក្រចេះ ដែលដីនោះមានទីតាំងនៅភូមិជ្រោយថ្មក្រោម ឃុំឆ្លង ស្រុកឆ្លង ខេត្តក្រចេះ នោះគឺពិតជាដីកម្មសិទ្ធិរបស់ឈ្មោះ [redacted] វាសនា ហើយការចាក់ដីរបស់ឈ្មោះ [redacted] សុខុន, ឈ្មោះ [redacted] ធារ៉ុង, ឈ្មោះ [redacted] សាមឿន, ឈ្មោះ [redacted] ឈង, ឈ្មោះ [redacted] គីមឆាន និងបក្ខពួក គឺពិតជាបានបំពានទៅលើដីកម្មសិទ្ធិរបស់ឈ្មោះ [redacted] វាសនា ប្រាកដមែន។

-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] ម៉ាឡៃ បានបញ្ជាក់ថា: កាលពីថ្ងៃទី៣១ ខែមករា ឆ្នាំ២០២១ ឈ្មោះ [redacted] ធារ៉ុង ភេទប្រុស អាយុ៤០ឆ្នាំ, ឈ្មោះ [redacted] សាមឿន ភេទប្រុស អាយុ៦២ឆ្នាំ, ឈ្មោះ [redacted] ឈង ភេទប្រុស អាយុ៧៣ឆ្នាំ, ឈ្មោះ [redacted] គីមឆាន ភេទប្រុស អាយុ៦៩ឆ្នាំ និងឈ្មោះ [redacted] សុខុន ភេទប្រុស អាយុ៥៧ឆ្នាំ គឺជាអ្នកចេញមុខក្នុងការចាក់ដីដោយមិនដឹងថាដីនោះមានទំហំប៉ុន្មាននោះទេ ប៉ុន្តែខ្ញុំគ្រាន់តែដឹងថាដីនោះស្ថិតនៅភូមិជ្រោយថ្មក្រោម ឃុំឆ្លង ស្រុកឆ្លង ខេត្តក្រចេះ ហើយខ្ញុំមិនដឹងថាអ្នកណាជាអ្នកចេញថ្លៃចាក់ដីនោះដែរ។ ខណៈពេលដែលកំពុងតែចាក់ដីនោះក៏ឃើញមានព្រះរាជអាជ្ញា និងមន្ត្រីជាច្រើននាក់ដោយមិនដឹងថាមានចំនួនប៉ុន្មាននោះទេ បានចុះទៅកន្លែងចាក់ដី ហើយបានសួរនាំខ្ញុំថា “តើអ្នកណាជាម្ចាស់ដី” រួចហើយក៏បានឱ្យខ្ញុំផ្តិតមេដៃនៅលើក្រដាសពណ៌សដោយមិនដឹងថាគេផ្តិតយកទៅធ្វើអ្វីនោះទេ។ ខ្ញុំគ្រាន់តែដឹងថាដីដែលឈ្មោះ [redacted] ធារ៉ុង ភេទប្រុស អាយុ៤០ឆ្នាំ, ឈ្មោះ [redacted] សាមឿន ភេទប្រុស អាយុ៦២ឆ្នាំ, ឈ្មោះ [redacted] ឈង ភេទប្រុស អាយុ៧៣ឆ្នាំ, ឈ្មោះ [redacted] គីមឆាន ភេទប្រុស អាយុ៦៩ឆ្នាំ និងឈ្មោះ [redacted] សុខុន ភេទប្រុស អាយុ៥៧ឆ្នាំ បានចាក់ដីនោះគឺជាដីរបស់កុងឈ្មោះ [redacted] រឿន និងប្រពន្ធឈ្មោះ [redacted] ឃឿន ដោយខ្ញុំមិនដឹងថាពួកគាត់បានចែកដីនោះទៅឱ្យអ្នកណាទេ។ សព្វថ្ងៃនេះដីនោះ គឺមិនបានចាក់បន្តទៀតទេ ហើយប្អូនជីដូនមួយរបស់ខ្ញុំឈ្មោះ [redacted] ស្រីពុំ ភេទស្រី អាយុ៣៨ឆ្នាំ និងប្តីឈ្មោះ ហោ អាយុ៣៧ឆ្នាំ មានទីលំនៅសព្វថ្ងៃនៅភូមិជ្រោយថ្មក្រោម ឃុំឆ្លង ស្រុកឆ្លង ខេត្តក្រចេះ គឺជាអ្នកធ្វើស្រែនៅលើដីនោះ។ នៅពេលដែលគេកំពុងតែចាក់ដីនោះ គឺខ្ញុំមិនបានចូលរួមធ្វើសកម្មភាពណាមួយឡើយ។

-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] ណារ៉ុន បានបញ្ជាក់ថា: កាលពីថ្ងៃទី ៣១ ខែមេសា ឆ្នាំ២០២១ ឈ្មោះ [redacted] ធារ៉ុង ភេទប្រុស អាយុ៤០ឆ្នាំ, ឈ្មោះ [redacted] សាមឿន ភេទប្រុស អាយុ៦២ឆ្នាំ, ឈ្មោះ [redacted] ឈង ភេទប្រុស អាយុ៧៣ឆ្នាំ, ឈ្មោះ [redacted] គីមឆាន ភេទប្រុស អាយុ៦៨ឆ្នាំ និងឈ្មោះ [redacted] សុខុន ភេទប្រុស អាយុ៥៧ឆ្នាំ គឺជាអ្នកចេញមុខក្នុងការចាក់ដីដោយមិនដឹងថាដីនោះមានទំហំប៉ុន្មាននោះទេ ប៉ុន្តែគ្រាន់តែដឹងថាដីនោះស្ថិតនៅភូមិជ្រោយថ្មក្រោម ឃុំឆ្នង ស្រុកឆ្នង ខេត្តក្រចេះ ហើយខ្លួនមិនដឹងថាអ្នកណាជាអ្នកចេញថ្លៃចាក់ដីនោះទេ ដោយដីនោះមិនទាន់មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុនោះទេ គឺមានត្រឹមតែលិខិតទទួលស្គាល់ត្រឹមភូមិឃុំប៉ុណ្ណោះ។ ខណៈពេលដែលកំពុងតែចាក់នោះក៏ឃើញមានព្រះរាជអាជ្ញា ក្រឡាបញ្ជីចំនួនម្នាក់ និងអធិការស្រុកឆ្នងឈ្មោះ តួ តែមិនស្គាល់ត្រកូលនោះទេ បានចុះទៅកន្លែងចាក់ដី ដើម្បីធ្វើការហាមឃាត់មិនឱ្យឈ្មោះ [redacted] ធារ៉ុង, ឈ្មោះ [redacted] សាមឿន, ឈ្មោះ [redacted] ឈង, ឈ្មោះ [redacted] សុខុន និងឈ្មោះ [redacted] គីមឆាន មិនឱ្យធ្វើសកម្មភាពចាក់ដីបន្តទៀត។ ខ្លួនគ្រាន់តែដឹងថាដីដែលឈ្មោះ [redacted] ធារ៉ុង ភេទប្រុស អាយុ៤០ឆ្នាំ, ឈ្មោះ [redacted] សាមឿន ភេទប្រុស អាយុ៦២ឆ្នាំ, ឈ្មោះ [redacted] ឈង ភេទប្រុស អាយុ៧៣ឆ្នាំ, ឈ្មោះ [redacted] គីមឆាន ភេទប្រុស អាយុ៦៩ឆ្នាំ និងឈ្មោះ [redacted] សុខុន ភេទប្រុស អាយុ៥៧ឆ្នាំ បានចាក់ដីនោះ គឺជាដីរបស់ឪពុកម្តាយឈ្មោះ [redacted] រឿន និងប្រពន្ធឈ្មោះ [redacted] ឃឿន បានចែកឱ្យកូនរបស់ពួកគាត់ ប៉ុន្តែខ្លួនមិនបានឮផ្ទាល់ត្រចៀកនោះទេ ដោយគ្រាន់តែបានឮ និងដឹងពីប៉ារបស់ឈ្មោះ [redacted] ឈង ប៉ុណ្ណោះ។ សព្វថ្ងៃនេះដីនោះ គឺមិនបានចាក់បន្តទៀតទេ ហើយដីនោះត្រូវបានបងប្អូនជីដូនមួយឈ្មោះ [redacted] ស្រីពុំ ភេទស្រី អាយុ៣៨ឆ្នាំ និងប្តីឈ្មោះ [redacted] សេងហោ អាយុ៣៧ឆ្នាំ មានទីលំនៅសព្វថ្ងៃនៅភូមិជ្រោយថ្មក្រោម ឃុំឆ្នង ស្រុកឆ្នង ខេត្តក្រចេះ គឺជាអ្នកបង្កបង្កើនផលនៅលើដីនោះ។ នៅពេលដែលគេចុះទៅធ្វើការហាមឃាត់ការចាក់ដីនោះគឺខ្លួនមិនបានធ្វើសកម្មភាពណាមួយឡើយ ហើយឈ្មោះ [redacted] ធារ៉ុង ក៏មានវត្តមាននៅទីនោះដែរ។ ចំណែកឯឈ្មោះ [redacted] សាមឿន, ឈ្មោះ [redacted] ឈង, ឈ្មោះ [redacted] សុខុន និងឈ្មោះ [redacted] គីមឆាន ពុំមានវត្តមានទេ។

-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] ស្រីពេជ្រ បានបញ្ជាក់ថា: កាលពីថ្ងៃទី៣១ ខែមេសា ឆ្នាំ២០២១ ឈ្មោះ [redacted] ធារ៉ុង ភេទប្រុស អាយុ៤០ឆ្នាំ, ឈ្មោះ [redacted] សាមឿន ភេទប្រុស អាយុ៦២ឆ្នាំ, ឈ្មោះ [redacted] ឈង ភេទប្រុស អាយុ៧៣ឆ្នាំ, ឈ្មោះ [redacted] គីមឆាន ភេទប្រុស អាយុ៦៨ឆ្នាំ និងឈ្មោះ [redacted] សុខុន ភេទប្រុស អាយុ៥៧ឆ្នាំ គឺជាអ្នកចេញមុខក្នុងការចាក់ដីដោយមិនដឹងថាដីនោះមានទំហំប៉ុន្មាននោះទេ ប៉ុន្តែគ្រាន់តែដឹងថាដីនោះស្ថិតនៅភូមិជ្រោយថ្មក្រោម ឃុំឆ្នង ស្រុកឆ្នង ខេត្តក្រចេះ ហើយខ្លួនដឹងថាពួកគាត់រួមគ្នាចេញថ្លៃចាក់ដីនោះ ដោយដីនោះមិនទាន់មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ

នោះទេ គឺមានត្រឹមតែលិខិតទទួលស្គាល់ត្រឹមភូមិឃុំប៉ុណ្ណោះ។ កាលពីថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២១ វេលាម៉ោងមួយរសៀល ក៏ឃើញមានព្រះរាជអាជ្ញា ក្រឡាបញ្ជីចំនួនបីនាក់ មន្ត្រីសុរិយោដីខេត្តចំនួនបួននាក់ គឺឈ្មោះ បូទុម និងឈ្មោះ [redacted] សុគុណ និងមន្ត្រីចំនួនពីរនាក់ទៀតមិនស្គាល់ឈ្មោះនោះទេ និងប៉ូលីសចំនួនប្រហែលប្រាំពីរនាក់ បានចុះទៅកន្លែងចាក់ដី ដើម្បីធ្វើការហាមឃាត់មិនឱ្យឈ្មោះ [redacted] ធារ៉ុង, ឈ្មោះ [redacted] សាមឿន, ឈ្មោះ [redacted] ឈង, ឈ្មោះ [redacted] សុខុន និងឈ្មោះ [redacted] គីមឆាន មិនឱ្យធ្វើសកម្មភាពចាក់ដីបន្តទៀត។ ខ្ញុំគ្រាន់តែដឹងថាដីដែលឈ្មោះ [redacted] ធារ៉ុង ភេទប្រុស អាយុ៤០ឆ្នាំ, ឈ្មោះ [redacted] សាមឿន ភេទប្រុស អាយុ៦២ឆ្នាំ, ឈ្មោះ [redacted] ឈង ភេទប្រុស អាយុ៧៣ឆ្នាំ, ឈ្មោះ [redacted] គីមឆាន ភេទប្រុស អាយុ៦៩ឆ្នាំ និងឈ្មោះ [redacted] សុខុន ភេទប្រុស អាយុ៥៧ឆ្នាំ បានចាក់ដីនោះ គឺជាដីរបស់កុងឈ្មោះ [redacted] រឿន និងប្រពន្ធឈ្មោះ [redacted] ឃឿន បានចែកឱ្យកូនរបស់ពួកគាត់ប៉ុន្តែខ្ញុំនមិនបានឮផ្ទាល់ត្រង់នោះទេ។ សព្វថ្ងៃនេះដីនោះ គឺមិនបានចាក់បន្តទៀតទេ ហើយដីបងស្រីបង្កើតរបស់ខ្ញុំឈ្មោះ [redacted] ស្រីម៉ង ហៅ ស្រីពុំ អាយុ៣៤ឆ្នាំ និងប្តីឈ្មោះ [redacted] សេងហោ អាយុ៣៧ឆ្នាំ មានទីលំនៅសព្វថ្ងៃនៅភូមិជ្រោយថ្មក្រោម ឃុំឆ្នង ស្រុកឆ្នង ខេត្តក្រចេះ គឺជាអ្នកបង្កបង្កើនផលនៅលើដីនោះ។ នៅពេលដែលគេចុះទៅធ្វើការហាមឃាត់ការចាក់ដីនោះ គឺខ្ញុំនមិនបានធ្វើសកម្មភាពណាមួយឡើយ។

-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] ធារ៉ុង ([redacted]ារ៉ុង) បានបញ្ជាក់ថា: កាលពីថ្ងៃទី៣១ ខែមករា ឆ្នាំ២០២១ ខ្ញុំន, ឈ្មោះ [redacted] សាមឿន, ឈ្មោះ [redacted] ឈង, ឈ្មោះ [redacted] គីមឆាន និងឈ្មោះ [redacted] សុខុន និងញាតិជាច្រើនទៀត បានឱ្យឡានដីកដីមកចាក់ដីដែលមានទីតាំងស្ថិតនៅភូមិជ្រោយថ្មក្រោម ឃុំឆ្នង ស្រុកឆ្នង ខេត្តក្រចេះ អស់ប្រហែល ៤០០ ទៅ៥០០ឡាន (ឡានមួយផ្ទុកបាន៥ម៉ែត្រគីប) មូលហេតុដែលខ្ញុំនចាក់ដីនោះដើម្បីការពារកុំឱ្យលិចទឹក ហើយទុកសម្រាប់ធ្វើតូបលក់អីវ៉ាន់ ដោយដីដែលខ្ញុំនចាក់នោះមានទំហំប្រហែល ៧.៦៩៧ម៉ែត្រការ៉េ ហើយការចាក់ដីនោះក៏ខ្ញុំនបានសុំច្បាប់ពីអាជ្ញាធរដែរ នៅពេលដែលខ្ញុំនដឹងថាការចាក់នោះរៀបនឹងបំពានចូលទៅលើដីឈ្មោះ [redacted] វាសនា ខ្ញុំនក៏បានផ្អាកការចាក់ដីបន្ថែមឈប់រហូតដល់ពេលនេះ ហើយនាពេលនោះដែរក៏មានតំណាងអយ្យការចុះអនុវត្តដីការរក្សាការពារហាមឃាត់លើការចាក់ដីនោះ។ ខ្ញុំនមិនមានចេតនាចាក់ដីបំពានទៅលើដីរបស់ឈ្មោះ [redacted] វាសនា ដែលមានទីតាំងនៅភូមិជ្រោយថ្មក្រោម ឃុំឆ្នង ស្រុកឆ្នង ខេត្តក្រចេះ នោះទេ ហើយចាប់តាំងពីពេលនោះមកខ្ញុំនឈប់ធ្វើសកម្មភាពចាក់ដីនោះរហូតមកដល់ពេលនេះ។ ដីរបស់ខ្ញុំនដែលជាកម្មសិទ្ធិផ្ទាល់ខ្ញុំននៅភូមិជ្រោយថ្មក្រោម ឃុំឆ្នង ស្រុកឆ្នង ខេត្តក្រចេះ គឺមានទំហំកាល១៥ និងបណ្តោយ៨០ ម៉ែត្រ ដោយដីនោះខ្ញុំនបានមកពីឈ្មោះ [redacted] រតនា (ជាឪពុកមា) ដែលបានប្រគល់ឱ្យខ្ញុំន

នៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៧ ដែលមានលិខិតផ្ទេរសិទ្ធិលេខ: ៦៨៧-០៧ ច.ណ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៧។

-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ[redacted] **ស្រេន** បានបញ្ជាក់ថា: កាលពីថ្ងៃទី ៣១ ខែមករា ឆ្នាំ២០២១ ឈ្មោះ[redacted]ឈង ភេទប្រុស អាយុ៧៣ឆ្នាំ, ឈ្មោះ[redacted] គីមឆាន ភេទប្រុស អាយុ៦៩ឆ្នាំ និងឈ្មោះ[redacted] ស្រីលាន ភេទស្រី អាយុប្រហែល៤០ឆ្នាំ និងបងប្អូនប្រហែលបីបួននាក់ទៀត គឺជាអ្នកដែលចេញមុខក្នុងការចាក់ដីលុបប្រឡាយរបស់ក្រុមហ៊ុនសាមលិញ ដែលមានបណ្តោយប្រវែងប្រហែល ៣០ម៉ែត្រ និងទទឹង ប្រហែល២០ ម៉ែត្រ ស្ថិតនៅភូមិជ្រោយថ្មក្រោម ឃុំឆ្នង ស្រុកឆ្នង ខេត្តក្រចេះ ហើយខ្ញុំដឹងថាពួកគាត់រួមគ្នា ចេញថ្លៃចាក់ដីនោះ ដោយដីនោះមិនទាន់មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុនោះទេ។ ការចាក់ដីរបស់ឈ្មោះ[redacted] ឈង, ឈ្មោះ[redacted]គីមឆាន និងឈ្មោះ[redacted] ស្រីលាន និងបងប្អូនបីបួននាក់នោះមិនបានបំពានចូលទៅក្នុងដីរបស់ឈ្មោះ[redacted] វាសនា នោះទេ គឺពួកគាត់បានចាកដីលុបប្រឡាយរបស់ក្រុមហ៊ុនសាមលិញតែប៉ុណ្ណោះ ហើយដីដែលពួកគាត់បានចាក់នោះ គឺជាដីរបស់ក្រុមហ៊ុនសាមលិញ។ ដីដែលឈ្មោះ[redacted]ឈង, ឈ្មោះ[redacted]គីមឆាន, ឈ្មោះ[redacted]ស្រីលាន និងបងប្អូនបីបួននាក់ បានឱ្យឡានដីកដីយកទៅចាក់នោះ គឺពុំមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុនោះទេ។

-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ[redacted] **គីមលាង** បានបញ្ជាក់ថា: ខ្ញុំនសូមឆ្លើយតែការពិតថាចំពោះឈ្មោះ[redacted]សាមឿន, ឈ្មោះ[redacted]ឈង, ឈ្មោះ[redacted]សុខុន និងឈ្មោះ[redacted]គីមឆាន បានប្តឹងជំទាស់អំពីការធ្វើប្តង់តាមប្រព័ន្ធរបស់ឈ្មោះ[redacted] វាសនា គឺខ្ញុំនបានដឹងថាខាងសាលាស្រុកបានហៅភាគីទាំងពីរ រួមទាំងអាជ្ញាធរទៅចូលរួមដោះស្រាយរួចហើយ ប៉ុន្តែខ្ញុំនមិនដឹងថាខាងសាលាស្រុកមានចំណាត់ការយ៉ាងណានោះទេ។ ចំពោះឈ្មោះ[redacted]សាមឿន, ឈ្មោះ[redacted]ឈង, ឈ្មោះ[redacted]សុខុន, ឈ្មោះ[redacted]ធារ៉ុង, ឈ្មោះ[redacted]ស្រីពិច, ឈ្មោះ[redacted]ម៉ាឡៃ, ឈ្មោះ[redacted]ណារ៉ុង និងឈ្មោះ[redacted]គីមឆាន បានចាក់ដី ឬមិនបានចាក់ដីរំលោភទៅលើដីរបស់ឈ្មោះ[redacted] វាសនា គឺខ្ញុំនមិនបានដឹងរឿងទេ ព្រោះបច្ចុប្បន្ននៅពេលមានប្រជាពលរដ្ឋចង់ចាក់ដី គឺពួកគាត់ត្រូវទៅសុំនៅច្រកចេញចូលតែមួយដែលហេតុនេះហើយទើបខ្ញុំនមិនដឹងរឿង។

-សាក្សីឈ្មោះ[redacted] **គីមចាំង** បានបញ្ជាក់ថា: ខ្ញុំនសូមឆ្លើយតែការពិតថាចំពោះឈ្មោះ[redacted]សាមឿន, ឈ្មោះ[redacted]ឈង, ឈ្មោះ[redacted]សុខុន និងឈ្មោះ[redacted]គីមឆាន បានប្តឹងជំទាស់អំពីការធ្វើប្តង់តាមប្រព័ន្ធរបស់ឈ្មោះ[redacted]វាសនា គឺខ្ញុំនមិនបានដឹងរឿងនោះទេ ហើយចំពោះករណីដែលឈ្មោះ[redacted]វាសនា បានប្តឹងឈ្មោះ[redacted]សាមឿន, ឈ្មោះ[redacted]ឈង, ឈ្មោះ[redacted]សុខុន និងឈ្មោះ[redacted]គីមឆាន ពីករណី គំរាមថានឹងសម្លាប់, ហិង្សា

ទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត, ការរារាំងក្នុងការចេញប្តង់តាមប្រព័ន្ធ និង ការធ្វើឱ្យខូចខាតក្នុងការចេញប្តង់ គឺខ្លួនមិនដឹងរឿងអ្វីទេ។ ចំពោះឈ្មោះ [redacted] សាមឿន, ឈ្មោះ [redacted] ឈង, ឈ្មោះ [redacted] សុខុន, ឈ្មោះ [redacted] ធារ៉ុង, ឈ្មោះ [redacted] ស្រីពិច, ឈ្មោះ [redacted] ម៉ាឡៃ, ឈ្មោះ [redacted] ណារ៉ុង និងឈ្មោះ [redacted] គីមឆាន បានចាក់ដី ឬមិនបានចាក់ដីរំលោភទៅលើដីរបស់ឈ្មោះ [redacted] វាសនា គឺខ្លួនមិនបានដឹងរឿងទេ ព្រោះបច្ចុប្បន្ននៅពេលមានប្រជាពលរដ្ឋចង់ចាក់ដី គឺពួកគាត់ត្រូវទៅសុំការអនុញ្ញាតទៅច្រកចេញចូលតែមួយ នៅសាលាស្រុកឆ្នូង ដោយហេតុនេះទើបខ្លួនមិនបានដឹងរឿង។

-សាក្សីឈ្មោះ [redacted] ប៊ុន្នីន បានបញ្ជាក់ថា: ខ្លួនសូមឆ្លើយតែការពិតថាចំពោះឈ្មោះ [redacted] សាមឿន, ឈ្មោះ [redacted] ឈង, ឈ្មោះ [redacted] សុខុន និងឈ្មោះ [redacted] គីមឆាន បានប្តឹងជំទាស់អំពីការធ្វើប្តង់តាមប្រព័ន្ធរបស់ឈ្មោះ [redacted] វាសនា គឺខ្លួនមិនបានដឹងរឿងនោះទេ ហើយចំពោះករណីដែលឈ្មោះ [redacted] វាសនា បានប្តឹងឈ្មោះ [redacted] សាមឿន, ឈ្មោះ [redacted] ឈង, ឈ្មោះ [redacted] សុខុន និងឈ្មោះ [redacted] គីមឆាន ពីករណី គំរាមថានឹងសម្លាប់, ហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត, ការរារាំងក្នុងការចេញប្តង់តាមប្រព័ន្ធ និង ការធ្វើឱ្យខូចខាតក្នុងការចេញប្តង់ គឺខ្លួនមិនដឹងរឿងអ្វីទេ។ ចំពោះឈ្មោះ [redacted] សាមឿន, ឈ្មោះ [redacted] ឈង, ឈ្មោះ [redacted] សុខុន, ឈ្មោះ [redacted] ធារ៉ុង, ឈ្មោះ [redacted] ស្រីពិច, ឈ្មោះ [redacted] ម៉ាឡៃ, ឈ្មោះ [redacted] ណារ៉ង និងឈ្មោះ [redacted] គីមឆាន បានចាក់ដី ឬមិនបានចាក់ដីរំលោភទៅលើដីរបស់ឈ្មោះ [redacted] វាសនា គឺខ្លួនមិនបានដឹងរឿងទេ ព្រោះបច្ចុប្បន្ននៅពេលមានប្រជាពលរដ្ឋចង់ចាក់ដី គឺពួកគាត់តែងតែ ទៅសុំការអនុញ្ញាតលោកមេឃុំ ដែលហេតុនេះហើយទើបខ្លួនមិនដឹងរឿង។

<u>សេចក្តីសន្និដ្ឋានរបស់មេធាវីតំណាងដោយអាណត្តិឱ្យដើមបណ្តឹងរដ្ឋប្បវេណី</u>

ក្រោយពីបានពិនិត្យសំណុំរឿង និងក្រោយពីបានស្តាប់ចម្លើយរបស់ជនរងគ្រោះ និងសាក្សី ព្រមទាំងឯកសារផ្សេងៗក្នុងសំណុំរឿង ឃើញថាកូនក្តីខ្លួនពិតជាបានរងការបំពានពីសំណាក់ជនជាប់ចោទ ដែលបានយកដីទៅចាក់ចូលដីកូនក្តីរបស់ខ្លួន និងដកបង្គោលព្រំដីរបស់កូនក្តីខ្លួន ដែលជាកម្មសិទ្ធិច្បាស់លាស់។ ហេតុដូចនេះ ស្នើសុំឱ្យតុលាការ សម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

<u>សេចក្តីសន្និដ្ឋានបិទសុំរបស់តំណាងអយ្យការ</u>

ក្រោយពីបានធ្វើការសួរដេញដោលរួចមកឃើញថា មានភស្តុតាងគ្រប់គ្រាន់ដែលអាចចោទប្រកាន់ទៅលើឈ្មោះ [redacted] **ឈង** ភេទប្រុស អាយុ៧៣ឆ្នាំ, ឈ្មោះ [redacted] **សុខុន** ភេទប្រុស អាយុ៥៧ឆ្នាំ, ឈ្មោះ [redacted] **គីមឆាន** ភេទប្រុស អាយុ៦៩ឆ្នាំ និងឈ្មោះ [redacted] **សាមឿន**

ភេទប្រុស អាយុ៦២ឆ្នាំ ពីបទៈ **ហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត** ប្រព្រឹត្ត នៅចំណុចភូមិជ្រោយថ្មក្រោម ឃុំឆ្នង ស្រុកឆ្នង ខេត្តក្រចេះ កាលពីថ្ងៃទី៣១ ខែមករា ឆ្នាំ២០២១។ ដូចនេះតំណាងអយ្យការសុំតម្កល់ការចោទប្រកាន់ដូចក្នុងដីកាសន្និដ្ឋានស្ថាពរ និងដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ និងប្តឹងសុំឱ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់កំណត់។

<u>សេចក្តីសន្និដ្ឋានប្តឹងសុំរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ</u>

ក្រោយពីបានពិនិត្យសំណុំរឿង និងឯកសារក្នុងសំណុំរឿងសព្វគ្រប់ឃើញថាកូនក្តីខ្ញុំឈ្មោះ [redacted] **ឈង** ភេទប្រុស អាយុ៧៣ឆ្នាំ ជាតិខ្មែរ, ឈ្មោះ [redacted] **សុខុន** ភេទប្រុស អាយុ៥៧ឆ្នាំ, ឈ្មោះ [redacted] **គីមឆាន** ភេទប្រុស អាយុ៦៩ឆ្នាំ និងឈ្មោះ [redacted] **សាមឿន** ភេទប្រុស អាយុ៦២ឆ្នាំ ពុំបានប្រព្រឹត្តបទល្មើស **ហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត**។ ក្នុងនាមខ្ញុំជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ស្នើសុំឱ្យតុលាការសម្រេចឱ្យកូនក្តីខ្ញុំរួចផុតពីបទចោទប្រកាន់ ដោយក្តីអនុគ្រោះបំផុត។

<u>សម្តីចុងក្រោយរបស់ជនជាប់ចោទ</u>

-ជនជាប់ចោទឈ្មោះ [redacted] **ឈង** បាននិយាយសម្តីចុងក្រោយថាៈ ខ្ញុំបាទសូមសំណូមពរឱ្យតុលាការមេត្តាលើកលែងទោសដល់រូបខ្ញុំបាទ។

-ជនជាប់ចោទឈ្មោះ [redacted] **សុខុន** បាននិយាយសម្តីចុងក្រោយថាៈ ខ្ញុំបាទសូមសំណូមពរឱ្យតុលាការមេត្តាលើកលែងទោសដល់រូបខ្ញុំបាទ។

-ជនជាប់ចោទឈ្មោះ [redacted] **គីមឆាន** បាននិយាយសម្តីចុងក្រោយថាៈ ខ្ញុំបាទសូមសំណូមពរឱ្យតុលាការមេត្តាលើកលែងទោសដល់រូបខ្ញុំបាទ។

-ជនជាប់ចោទឈ្មោះ [redacted] **សាមឿន** បាននិយាយសម្តីចុងក្រោយថាៈ ខ្ញុំបាទសូមសំណូមពរឱ្យតុលាការមេត្តាលើកលែងទោសដល់រូបខ្ញុំបាទ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណី, សាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីតំណាងដោយអាណត្តិឱ្យដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

សំអាងហេតុ

១-យល់ឃើញថា: ផ្អែកតាមដីកាដំណោះសម្រេចបញ្ជូនសំណុំរឿងមកជំនុំជម្រះ បានបញ្ជូនជនជាប់ចោទឈ្មោះ[redacted] ឈង, [redacted] សុខុន, [redacted] គីមឆាន និងឈ្មោះ[redacted] សាមឿន មកជំនុះជម្រះពីបទ: **ហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត** ប្រព្រឹត្តនៅចំណុចភូមិជ្រោយថ្មក្រោម ឃុំឆ្នង ស្រុកឆ្នង ខេត្តក្រចេះ កាលពីថ្ងៃទី៣១ ខែមករា ឆ្នាំ ២០២១។

២-យល់ឃើញថា: ផ្អែកតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ឈង, ឈ្មោះ [redacted] សុខុន, ឈ្មោះ[redacted] គីមឆាន និងឈ្មោះ[redacted] សាមឿន បានបញ្ជាក់ចម្លើយគ្រប់ដំណាក់កាល (ដំណាក់កាលអយ្យការ, ដំណាក់កាលចៅក្រមស៊ើបសួរ និងដំណាក់កាលចៅក្រមជំនុំជម្រះ) ថា កាលដែលពួកខ្លួនបានចាក់ដីចូលទៅក្នុងប្រឡាយ ដោយសារតែពួកខ្លួនយល់ឃើញថា បានស្នើសុំអាជ្ញាធរពិតមែន ដែលក្នុងនោះឈ្មោះ[redacted] ធារ៉ុង ([redacted] ភារ៉ុង) ជាអ្នកស្នើសុំ។ ពួកខ្លួនគ្មានចេតនាបំពានលើដីរបស់ឈ្មោះ[redacted] វាសនា នោះទេ ម៉្យាងទៀត ពេលដែលអាជ្ញាធរចុះហាមឃាត់ ពួកខ្លួនមិនបានប្រើហិង្សា និងបានបញ្ឈប់សកម្មភាពចាក់ដីដែរ។

៣-យល់ឃើញថា: ឈ្មោះ[redacted] ធារ៉ុង ([redacted] ភារ៉ុង) ដែលជាអ្នកស្នើសុំអាជ្ញាធរចាក់បំពេញដីត្រូងបានលើកលែងចោទប្រកាន់តាមដីកាដំណោះស្រាយ និងត្រូវបានសាលាឧទ្ធរណ៍ និងតុលាការកំពូល សម្រេចឥម្ពល់សេចក្តី នៃដីកាដំណោះស្រាយលើកលែងចោទប្រកាន់។ មួយវិញទៀត តាមរយៈភស្តុតាងដែលមានក្នុងសំណុំរឿងឃើញថា វិវាទដីធ្លីរវាងជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី កំពុងដោះស្រាយគ្នានៅតុលាការជាន់ខ្ពស់ ពាក់ព័ន្ធនឹងសេចក្តីសម្រេចផ្នែករដ្ឋប្បវេណី។ នៅក្នុងករណីនេះ ភាគីទាំងពីរសុទ្ធតែមានឯកសារជៀងខ្លួន ដោយដើមបណ្តឹងរដ្ឋប្បវេណី មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ និងជនជាប់ចោទមានលិខិតកាន់កាប់ ព្រមទាំងឯកសារស្នើសុំចាក់ដី។

៤-យល់ឃើញថា: សកម្មភាពរបស់ជនជាប់ចោទ គ្មានភស្តុតាងណាមួយបញ្ជាក់ថាជនជាប់ចោទបានប្រព្រឹត្តបទល្មើស ប្រើអំពើហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិតនោះទេ ម៉្យាងទៀតបទល្មើសនេះ ពុំអាចចាត់ចូលជាអំពើល្មើសព្រហ្មទណ្ឌបានឡើយ ជាករណីវិវាទកម្មសិទ្ធិតែប៉ុណ្ណោះ ហើយចាប់តាំងពីមានបញ្ហាមកជនជាប់ចោទមិនដែលបានចាក់ដីប្រឡាយនោះម្តងទៀតឡើយ។

៥-យល់ឃើញថា: គ្មានភស្តុតាងជាក់បន្ទុកគ្រប់គ្រាន់ ដែលអាចបញ្ជាក់ថាជនជាប់ចោទឈ្មោះ[redacted] ឈង, [redacted] សុខុន, [redacted] គីមឆាន និងឈ្មោះ[redacted] សាមឿន បានប្រព្រឹត្តបទល្មើសទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត ប្រព្រឹត្តនៅភូមិជ្រោយថ្មក្រោម ឃុំឆ្នង

Scanned with CamScanner

ស្រុកឆ្លូង ខេត្តក្រចេះ កាលពីថ្ងៃទី៣១ ខែមករា ឆ្នាំ២០២១ ដែលត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៥២ នៃច្បាប់ភូមិបាល នោះឡើយ គប្បីតុលាការពិនិត្យ និងសម្រេចតាមច្បាប់។

ខ-យល់ឃើញថា: សំដីចុងក្រោយរបស់ជនជាប់ចោទ និងសេចក្តីសន្និដ្ឋានប្តឹងសុំរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ គប្បីតុលាការពិចារណាលើការប្រព្រឹត្ត អាកប្បកិរិយា និងច្បាប់ជាធរមាន។

<u>ហេតុដូច្នេះសម្រេច</u>

១-ឱ្យជនជាប់ចោទ÷

ក-ឈ្មោះ [redacted]**ឈង** ភេទប្រុស អាយុ៧៣ឆ្នាំ ជាតិខ្មែរ (អត្តសញ្ញាណខាងលើ)

ខ-ឈ្មោះ [redacted] **សុខុន** ភេទប្រុស អាយុ៥៧ឆ្នាំ ជាតិខ្មែរ (អត្តសញ្ញាណខាងលើ)

គ-ឈ្មោះ [redacted]**គីមឆាន** ភេទប្រុស អាយុ៦៩ឆ្នាំ ជាតិខ្មែរ (អត្តសញ្ញាណខាងលើ)

ឃ-ឈ្មោះ [redacted] **សាមឿន** ភេទប្រុស អាយុ៦២ឆ្នាំ ជាតិខ្មែរ (អត្តសញ្ញាណខាងលើ)

រួចផុតពីបទចោទប្រកាន់ ពីបទ: **ហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត** ប្រព្រឹត្តនៅចំណុចភូមិជ្រោយថ្មក្រោម ឃុំឆ្លូង ស្រុកឆ្លូង ខេត្តក្រចេះ កាលពីថ្ងៃទី៣១ ខែមករា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **២៥៣** នៃច្បាប់ភូមិបាល។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៣ ចំពោះមុខជនជាប់ចោទ និងកំពាំងមុខដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២៣។

បើកសិទ្ធប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

ក្រឡាបញ្ជីសវនាការ
ហត្ថលេខា និងត្រា
[redacted]

ចៅក្រមជំនុំជម្រះ
ហត្ថលេខា និងត្រា
[redacted]

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃព្រហស្បតិ៍ ១០រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧
ក្រចេះ, ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២៣

បានឃើញ
ចៅក្រមជំនុំជម្រះ
[redacted]

ក្រឡាបញ្ជីសវនាការ
[redacted]

Scanned with CamScanner